# ផែនការគ្រួសារ៖ ការមានកូនតាមបំណង

ជំពូកទី ២០

គ្រួសារទាំងពីរនេះរស់នៅក្នុងសហគមន៍ក្រីក្រ

*គ្រួសារនេះរស់នៅក្នុងតំបន់ដែលមានការបែងចែកធនធានផ្សេងៗមិនស្មើគ្នា។ គ្រួសារនេះមានកូនច្រើន ។*



*គ្រួសារនេះរស់នៅក្នុងតំបន់ដែលមានការបែងចែកធនធានផ្សេងៗស្មើៗគ្នា។ គ្រួសារនេះមានកូនតែពីរបីនាក់។*



ឪពុកម្តាយមួយចំនួនចង់បានកូនច្រើន ជាពិសេសនៅប្រទេសដែលប្រជាជនក្រីក្រមិនបានទទួលការបែងចែកដោយយុត្តិធម៌នូវដីធ្លី ធនធានផ្សេងៗ និង អត្ថប្រយោជន៍ដទៃទៀតក្នុងសង្គម។ ការចង់មានកូនច្រើននេះ ដោយសារតែកូនទាំងនោះអាចជួយធ្វើការងារ និងថែរទាំឪពុកម្តាយនៅពេលពួកគាត់មានវ័យចំណាស់។ នៅក្នុងតំបន់បែបនេះ ការមានកូនតែពីរបីនាក់ អាចជាអភ័យឯកសិទ្ធិរបស់អ្នកមានទ្រព្យសម្បត្តិដែលអាចរ៉ាប់រងបានតែប៉ុណ្ណោះ។

ស្ថានភាពនេះខុសគ្នាពីប្រទេសក្រីក្រដែលធនធាននិងអត្ថប្រយោជន៍ផ្សេងៗត្រូវបានបែងចែកដោយស្មើភាពគ្នា។ នៅតំបន់ដែលការងារ លំនៅដ្ឋាន និងការថែទាំសុខភាព មានការធានារ៉ាប់រង ហើយស្ត្រីមានឱកាសស្មើគ្នាក្នុងការទទួលការអប់រំ និងការងារ នោះប្រជាជនតែងតែជ្រើសរើសយកការមានគ្រួសារតូច។ មួយផ្នែកនៃមូលហេតុនេះ គឺដោយសារតែពួកគេមិនត្រូវការពឹងផ្អែកលើសុវត្ថិភាពសេដ្ឋកិច្ចរបស់កូនរបស់ពួកគេ។

នៅក្នុងគ្រប់សង្គមទាំងអស់ ឪពុកម្តាយមានសិទ្ធិធ្វើការសម្រេចចិត្តអំពីចំនួនកូនដែលពួកគេចង់បាន និងពេលដែលត្រូវមានកូនទាំងនោះ។

ឪពុកម្តាយផ្សេងគ្នាមានហេតុផលផ្សេងៗគ្នា ចំពោះការចង់កំណត់ទំហំគ្រួសារ។ ឪពុកម្តាយដែលមានវ័យក្មេងមួយចំនួន អាចសម្រេចចិត្តពន្យារពេលមានកូនរហូតដល់ពេលពួកគេបានធ្វើការនិងសន្សំលុយបានគ្រប់គ្រាន់ ដើម្បីអាចផ្តល់ការថែទាំដល់កូនរបស់ពួកគេឲ្យបានល្អ។ ឪពុកម្តាយខ្លះអាចសម្រេចចិត្តមានកូនតិច ហើយពួកគេមិនត្រូវការកូនបន្ថែមទៀតឡើយ។ អ្នកខ្លះទៀតអាចចង់ពន្យារពេលពីកូនមួយទៅកូនមួយឲ្យបានច្រើនឆ្នាំពីគ្នា ដើម្បីឲ្យម្តាយនិងកូនមានសុខភាពល្អ។ មានឪពុកម្តាយមួយចំនួនទៀតគិតថាពួកគាត់មានវ័យចាស់ហួសពីមានកូនបន្ថែមទៀត។ នៅតំបន់ខ្លះ បុរសនិងស្ត្រីដឹងថាបើពួកគេមានកូនច្រើន នៅពេលដែលកូនទាំងនោះធំឡើង ពួកគេនឹងគ្មានដីធ្លីគ្រប់គ្រាន់សម្រាប់ឲ្យកូនៗរបស់គេ ដាំដំណាំដែលគ្រួសាររបស់គេត្រូវការ។

# ផែនការគ្រួសារ



ការមានកូនតាមចំនួនដែលអ្នកត្រូវការ និងពេលដែលអ្នកចង់បាននេះ ហៅថា ផែនការគ្រួសារ។ បើអ្នកសម្រេចចិត្តរង់ចាំ អ្នកអាចជ្រើសរើសវិធីសាស្ត្រណាមួយ ដើម្បីបង្ការការមានផ្ទៃពោះ។ វិធីសាស្ត្រទាំងនេះ ហៅថា **វិធីសាស្ត្រក្នុងការធ្វើផែនការគ្រួសារ វិធីពន្យារកំណើត ឬវិធីបង្ការការមានផ្ទៃពោះ។**

ជារៀងរាល់ឆ្នាំមានស្ត្រីកន្លះលាននាក់បានស្លាប់ដោយសារបញ្ហាផ្សេងៗនៃការមានផ្ទៃពោះ ការសម្រាលកូន និងការរំលូតកូនដោយគ្មានសុវត្ថិភាព។ ការស្លាប់ទាំងនេះភាគច្រើនអាចបង្ការបានតាមរយៈការធ្វើផែនការគ្រួសារ។ ឧទាហរណ៍ ផែនការគ្រួសារអាចបង្ការគ្រោះថ្នាក់ពីការមានផ្ទៃពោះដែល ៖

- កើតលើស្ត្រីវ័យក្មេង។ ស្ត្រីដែលមានអាយុក្រោម១៧ឆ្នាំ មានការប្រឈមនឹងការស្លាប់ក្នុងពេលសម្រាល ព្រោះរាងកាយរបស់ពួកគេមិនទាន់មានការលូតលាស់ពេញលេញនៅឡើយ។ កូនរបស់គេមានការប្រឈមខ្ពស់នឹងការស្លាប់ក្នុងឆ្នាំដំបូងនៃជីវិត។
- កើតលើស្ត្រីវ័យចំណាស់។ ស្ត្រីវ័យចំណាស់មានការប្រឈមនឹងគ្រោះថ្នាក់ខ្ពស់ក្នុងពេលសម្រាលកូន ជាពិសេសបើពួកគេមានបញ្ហាសុខភាពផ្សេងៗទៀត ឬមានកូនច្រើន។
- ជាប់ៗគ្នាពេក។ រាងកាយរបស់ស្ត្រីត្រូវការពេលវេលាដើម្បីស្តារសុខភាពឡើងវិញ នៅចន្លោះការមានផ្ទៃពោះនីមួយៗ។
- ច្រើនពេក។ ស្ត្រីដែលមានកូនលើសពី៤នាក់ មានការប្រឈមខ្ពស់នឹងការស្លាប់ក្រោយពេលសម្រាលកូនដោយការធ្លាក់ឈាម និងមូលហេតុផ្សេងៗទៀត។

មានស្ត្រីរាប់លាននាក់បានប្រើប្រាស់វិធីពន្យារកំណើត ដែលបានរៀបរាប់នៅក្នុងជំពូកនេះ និងនៅទំព័រ៣៩៤ ដល់ ៣៩៧ ប្រកបដោយសុវត្ថិភាព។

# ការជ្រើសរើសវិធីពន្យារកំណើត

នៅទំព័របន្តបន្ទាប់នេះ នឹងមានការរៀបរាប់អំពីវិធីសាស្ត្រជាច្រើននៃផែនការគ្រួសារ។វិធីសាស្ត្រនីមួយៗមានប្រសិទ្ធភាព ល្អសម្រាប់មនុស្សផ្សេងៗគ្នា។ សិក្សាទំព័រទាំងនេះ ហើយពិភាក្សាជាមួយឆ្មប បុគ្គលិកសុខាភិបាល ឬគ្រូពេទ្យអំពីវិធីសាស្ត្រ ដែលអាចធ្វើបាន និងមានប្រសិទ្ធភាពល្អបំផុតសម្រាប់អ្នក។ នៅពេលដែលអ្នកអានអំពីវិធីសាស្ត្រនីមួយៗ ខាងក្រោមនេះ គឺជាសំនួរមួយចំនួនដែលអ្នកអាចពិចារណា ៖

- តើវាអាចបង្ការការមានផ្ទៃពោះបានល្អប៉ុនណា? តើវាមានប្រសិទ្ធភាពយ៉ាងដូចម្តេច?
- តើវាអាចបង្ការជំងឺកាមរោគបានប៉ុនណា?
- តើវាមានសុវត្ថិភាពប៉ុនណា? បើស្ត្រីមានបញ្ហាសុខភាពណាមួយដូចបានរៀបរាប់ក្នុងជំពូកនេះ នោះគាត់ប្រហែលជាត្រូវជៀសវាងប្រើប្រាស់វិធីពន្យារកំណើតមួយចំនួន។
- តើវាងាយស្រួលប្រើប៉ុនណា?
- តើវាមានតម្លៃប៉ុន្មាន?
- តើវាងាយស្រួលរកឬទេ? តើអ្នកនឹងត្រូវទៅមណ្ឌលសុខភាពញឹកញាប់ឬទេ?
- តើផលរំខានរបស់វា(បញ្ហាដែលអាចកើតឡើងដោយសារការប្រើប្រាស់វិធីសាស្ត្រណាមួយ) នឹងបង្កបញ្ហាដល់អ្នកឬទេ?

វិធីពន្យារកំណើត នឹងមានប្រសិទ្ធភាពបំផុត នៅពេលដែលបុរសនិងស្ត្រីមានការទទួលខុសត្រូវចំពោះការបង្ការការមានផ្ទៃពោះ និងការពារគ្នាទៅវិញទៅមកពីការចម្លងជំងឺកាមរោគ។

| វិធីពន្យារកំណើត | ការបង្ការការមានផ្ទៃពោះ | ការបង្ការជំងឺកាមរោគ | ផលរំខានដែលអាចកើតមាន | ព័ត៌មានសំខាន់ៗ |
|---|---|---|---|---|
| ស្រោមអនាម័យសម្រាប់បុរស  | ★★★ ល្អណាស់ | ល្អ | | មានប្រសិទ្ធភាពបំផុតនៅពេលប្រើជាមួយថ្នាំសម្លាប់មេជីវិតឈ្មោល និងទឹករំអិល (វត្ថុរាវសម្រាប់ជ្រមស្រោមអនាម័យ)។ |
| ស្រោមអនាម័យសម្រាប់ស្ត្រី  | ★★ ល្អ | ល្អ | | មិនសូវមានប្រសិទ្ធភាពនៅពេលស្ត្រីនៅពីលើបុរសក្នុងពេលរួមភេទ។ |
| សន្ទះដ្យ៉ាហ្វ្រាម (ដោយមានថ្នាំសម្លាប់មេជីវិតឈ្មោល)  | ★★ ល្អ | ខ្លះៗ | | មានប្រសិទ្ធភាពបំផុតនៅពេលប្រើជាមួយថ្នាំសម្លាប់មេជីវិតឈ្មោល។ |
| ថ្នាំសម្លាប់មេជីវិតឈ្មោល  | ★ ខ្លះៗ | ខ្លះៗ | ប្រតិកម្មស្បែក | មានប្រសិទ្ធភាពបំផុត នៅពេលប្រើជាមួយវិធីសាស្ត្រផ្សេងទៀត ដូចជាសន្ទះដ្យ៉ាហ្វ្រាម ឬស្រោមអនាម័យ |
| កងដាក់នៅដៃ  | ★★★★ ប្រសើរបំផុត | គ្មាន | ចង្អោរ ឈឺក្បាល រដូវប្រចាំខែមានការប្រែប្រួល។ | វិធីនេះអាចមានគ្រោះថ្នាក់ចំពោះស្ត្រីមានបញ្ហាសុខភាពខ្លះ។ ពិគ្រោះយោបល់ជាមួយបុគ្គលិកសុខាភិបាល។ |
| ថ្នាំចាក់ពន្យារកំណើត  | ★★★★ ប្រសើរបំផុត | គ្មាន | ចង្អោរ ឈឺក្បាល រដូវប្រចាំខែមានការប្រែប្រួល។ | វិធីនេះអាចមានគ្រោះថ្នាក់ចំពោះស្ត្រីមានបញ្ហាសុខភាពខ្លះ។ ពិគ្រោះយោបល់ជាមួយបុគ្គលិកសុខាភិបាល។ |
| ថ្នាំគ្រាប់ពន្យារកំណើត  | ★★★★ ប្រសើរបំផុត | គ្មាន | ចង្អោរ ឈឺក្បាល រដូវប្រចាំខែមានការប្រែប្រួល។ | វិធីនេះអាចមានគ្រោះថ្នាក់ចំពោះស្ត្រីមានបញ្ហាសុខភាពខ្លះ។ ពិគ្រោះយោបល់ជាមួយបុគ្គលិកសុខាភិបាល។ |
| វិធីពិនិត្យមើលទឹករំអិល  | ★★ ល្អ | គ្មាន | | ដើម្បីប្រើប្រាស់វិធីសាស្ត្រនេះឲ្យបានត្រឹមត្រូវ ស្ត្រីត្រូវតែដឹងអំពីពេលណាគាត់អាចមានការបង្កកំណើត។ |
| ការបំបៅកូនដោយទឹកដោះម្តាយ (ក្នុងអំឡុងពេល ៦ខែដំបូងប៉ុណ្ណោះ)  | ★★ ល្អ | គ្មាន | | ដើម្បីប្រើប្រាស់វិធីសាស្ត្រនេះ ស្ត្រីត្រូវតែបំបៅកូនដោយទឹកម្តាយសុទ្ធ ហើយ គាត់មិនទាន់មានរដូវវិញ។ |
| ការដកលិង្គចេញ  | ★ ខ្លះៗ | ខ្លះៗ | | មានប្រសិទ្ធភាពបំផុតពេលប្រើជាមួយវិធីផ្សេងទៀតដូចជាថ្នាំសម្លាប់មេជីវិតឈ្មោល ឬសន្ទះដ្យ៉ាហ្វ្រាម។ |
| កងដាក់ក្នុងស្បូន  | ★★★★ ប្រសើរបំផុត | គ្មាន | ធ្លាក់ឈាមរដូវយ៉ាងច្រើន និងមានការ ឈឺចាប់ | វិធីនេះអាចមានគ្រោះថ្នាក់ចំពោះស្ត្រីមានបញ្ហាសុខភាពខ្លះ។ ពិគ្រោះយោបល់ជាមួយបុគ្គលិកសុខាភិបាល។ |
| ការវះកាត់បញ្ឈប់កំណើតអចិន្ត្រៃយ៍  | ★★★★ ប្រសើរបំផុត | គ្មាន | | បុរសឬស្ត្រីមិនអាចមានកូនទៀតឡើយបន្ទាប់ពីការវះកាត់នេះហើយ។ |

# ថ្នាំគ្រាប់ពន្យារកំណើត(ថ្នាំលេបមិនឲ្យមានកូន)

ថ្នាំគ្រាប់ពន្យារកំណើតត្រូវបានផលិតមកពីជាតិគីមី(អ័រម៉ូន)ដែលមានជាធម្មតានៅក្នុងខ្លួនរបស់ស្ត្រី។ នៅពេលលេបថ្នាំបានត្រឹមត្រូវ ការប្រើថ្នាំគ្រាប់នេះគឺជាវិធីសាស្ត្រដ៏មានប្រសិទ្ធភាពបំផុតមួយ ក្នុងការបង្ការការមានផ្ទៃពោះ។ ទោះជាយ៉ាងនេះក៏ដោយ មានស្ត្រីខ្លះមិនគួរប្រើថ្នាំគ្រាប់ពន្យារកំណើតនេះទេ បើគាត់អាចប្រើវិធីសាស្ត្រណាមួយផ្សេងទៀតបាន (មើលទំ.២៨៨)។ ថ្នាំគ្រាប់ពន្យារកំណើតមិនអាចបង្ការជំងឺអេដស៍ ឬជំងឺកាមរោគទេ។ ដើម្បីបង្ការជំងឺទាំងនេះ ប្រើស្រោមអនាម័យ(ទំ.២៩០)។ បើអាច ការប្រើថ្នាំគ្រាប់ពន្យារកំណើតគួរត្រូវបានណែនាំដោយបុគ្គលិកសុខាភិបាល ឆ្មប ឬអ្នកដែលបានទទួលការបណ្តុះបណ្តាលក្នុងការប្រើប្រាស់ថ្នាំទាំងនេះប៉ុណ្ណោះ។

ជាធម្មតា ថ្នាំគ្រាប់នេះមានមកជាបន្ទះដែលមាន២១ឬ២៨គ្រាប់។ ជាទូទៅ បន្ទះដែលមាន២១គ្រាប់ តែងតែមានតម្លៃថោកជាង ហើយក្នុងចំណោមថ្នាំនេះ មានផលិតផលរបស់ក្រុមហ៊ុនខ្លះអាចថោកជាងផលិតផលរបស់ក្រុមហ៊ុនខ្លះទៀត។ បរិមាណរបស់ថ្នាំខុសៗគ្នាទៅតាមក្រុមហ៊ុនផលិត។ ដើម្បីជ្រើសរើសប្រភេទដែលត្រឹមត្រូវសម្រាប់អ្នក មើលទំព័រប៉ៃតងនៅទំព័រ៣៩៤ និង៣៩៥។







*វិធីលេបថ្នាំគ្រាប់ពន្យារកំណើត ៖ បន្ទះ២១គ្រាប់*

លេបគ្រាប់ដំបូងនៅថ្ងៃទី៥នៃការចាប់ផ្តើមមានរដូវរបស់អ្នក ដោយរាប់ថ្ងៃដំបូងនៃការធ្លាក់ឈាមរដូវ ជាថ្ងៃទី១។ បន្ទាប់មកលេប ១ថ្ងៃ១គ្រាប់ជារៀងរាល់ថ្ងៃ រហូតដល់អស់មួយបន្ទះ(២១ថ្ងៃ)។ **លេបថ្នាំគ្រាប់របស់អ្នកនៅម៉ោងដដែលជារៀងរាល់ថ្ងៃ។**

បន្ទាប់ពីអស់ថ្នាំពីបន្ទះហើយ រងចាំ៧ថ្ងៃទៀតមុននឹងចាប់ផ្តើមលេបថ្នាំបន្តទៀត។ បន្ទាប់មក ចាប់ផ្តើមប្រើបន្ទះថ្មីមួយទៀត ១គ្រាប់មួយថ្ងៃ។

តាមរបៀបនេះ អ្នកនឹងលេបថ្នាំគ្រាប់រយៈពេល៣អាទិត្យក្នុងខែនីមួយៗ បន្ទាប់មក ឈប់លេប១អាទិត្យ។ ជាធម្មតា ឈាមរដូវនឹងធ្លាក់មកក្នុងអំឡុងសប្តាហ៍ដែលមិនលេបថ្នាំនោះ។ បើទោះបីជាឈាមរដូវមិនធ្លាក់មកក៏ដោយ ចាប់ផ្តើមលេបថ្នាំបន្ទះថ្មី បន្ទាប់ពីបានឈប់លេបរយៈពេល៧ថ្ងៃ។

**បើអ្នកមិនចង់មានផ្ទៃពោះ វាជាការសំខាន់ណាស់ដែលត្រូវលេបថ្នាំតាមការណែនាំ គឺ១ថ្ងៃលេប១គ្រាប់ជារៀងរាល់ថ្ងៃ។** បើអ្នកភ្លេចលេបថ្នាំ១ថ្ងៃ លេបភ្លាមៗពេលដែលអ្នកនឹកឃើញ ឬលេប២គ្រាប់នៅថ្ងៃបន្ទាប់។

*វិធីលេបថ្នាំគ្រាប់ពន្យារកំណើត ៖ បន្ទះ២៨គ្រាប់*

លេបគ្រាប់ដំបូងនៅថ្ងៃទី៥នៃការធ្លាក់ឈាមរដូវ ដូចការលេបថ្នាំបន្ទះ២១គ្រាប់ដែរ។ លេប១គ្រាប់ក្នុង១ថ្ងៃ។ ថ្នាំ៧គ្រាប់ក្នុងបន្ទះនេះ មានទំហំនិងពណ៌ខុសពីគេ។ លេបថ្នាំ៧គ្រាប់នេះក្រោយគេ (១ថ្ងៃ១គ្រាប់) បន្ទាប់ពីបានលេបគ្រាប់ឯទៀតអស់។ នៅថ្ងៃដែលអ្នកបានបញ្ចប់ថ្នាំបន្ទះ២៨គ្រាប់នេះហើយ ចាប់ផ្តើមប្រើបន្ទះថ្មីមួយទៀតតែម្តង។ លេប១ថ្ងៃ១គ្រាប់ដោយគ្មានរំលងមួយថ្ងៃណាឡើយ មួយបន្ទះហើយមួយបន្ទះទៀត លេបជាប់ជានិច្ច បើអ្នកមិនចង់មានផ្ទៃពោះ។

គ្មានការតមអាហារពិសេសទេ ក្នុងពេលប្រើថ្នាំគ្រាប់ពន្យារកំណើតនេះ។ ទោះបីជាអ្នកកើតជំងឺផ្តាសាយ ឬមានជំងឺធម្មតាផ្សេងៗទៀត នៅពេលកំពុងប្រើថ្នាំគ្រាប់នេះក៏ដោយ បន្តលេបវាដដែល។ បើអ្នកឈប់លេបថ្នាំមុនពេលអស់ថ្នាំក្នុងបន្ទះ អ្នកអាចមានផ្ទៃពោះបាន។

**ផលរំខាន ៖**

ស្ត្រីខ្លះមានការក្អួតចង្អោរបន្តិចបន្តួចនៅពេលព្រឹក មានការឡើងដោះ ឬមានរោគសញ្ញាផ្សេងៗនៃការមានផ្ទៃពោះ នៅពេលដែលពួកគេចាប់ផ្ដើមលេបថ្នាំនេះជាលើកដំបូង។ បញ្ហានេះគឺដោយសារតែថ្នាំនេះមានជាតិគីមី(អ័រម៉ូន)ដូចគ្នា ដែលរាងកាយរបស់ស្ត្រីបញ្ចេញទៅក្នុងឈាមរបស់គាត់នៅពេលគាត់មានផ្ទៃពោះ។ រោគសញ្ញាទាំងអស់មិនមែនមានន័យថាគាត់គ្មានសុខភាពល្អ ឬគាត់គប្បីឈប់លេបថ្នាំនោះទេ។ ជាទូទៅ វានឹងបាត់ទៅវិញក្នុងរយៈពេល២ឬ៣ខែដំបូង។ បើរោគសញ្ញាទាំងអស់នោះមិនបាត់ទៅវិញទេ គាត់ប្រហែលជាត្រូវប្ដូរទៅប្រើប្រភេទថ្នាំដែលមានបរិមាណអ័រម៉ូនផ្សេងវិញ។ បញ្ហានេះត្រូវបានពិភាក្សានៅក្នុងទំព័របៃតង(ទំ.៣៩៤ និង៣៩៥)

ស្ត្រីជាច្រើនមានការធ្លាក់ឈាមរដូវប្រចាំខែតិចជាងធម្មតា នៅពេលដែលគាត់កំពុងប្រើថ្នាំនេះ។ ការផ្លាស់ប្ដូរនេះគ្មានអ្វីសំខាន់ទេ។

**"តើការលេបថ្នាំគ្រាប់ពន្យារកំណើតមានគ្រោះថ្នាក់ឬទេ?"**

ដូចថ្នាំផ្សេងៗទៀតដែរ ថ្នាំគ្រាប់ពន្យារកំណើតអាចបណ្ដាលឲ្យមានបញ្ហាធ្ងន់ធ្ងរចំពោះស្ត្រីមួយចំនួន(មើលទំព័របន្ទាប់)។ បញ្ហាធ្ងន់ធ្ងរបំផុតដែលទាក់ទងនឹងថ្នាំនេះ គឺការមានដុំកំណកឈាមនៅក្នុងបេះដូង សួត ឬខួរក្បាល (មើលជំងឺដាច់សរសៃឈាមខួរក្បាល ទំ.៣២៧)។ បញ្ហានេះច្រើនកើតឡើងចំពោះស្ត្រីដែលមានអាយុលើសពី៣៥ឆ្នាំ ហើយជក់បារី។ ទោះជាយ៉ាងនេះក៏ដោយ ឱកាសនៃការមានដុំកំណកឈាមនេះ មានកម្រិតខ្ពស់ចំពោះស្ត្រីនៅពេលមានផ្ទៃពោះ ជាងនៅពេលប្រើថ្នាំពន្យារកំណើត។ ប៉ុន្តែចំពោះស្ត្រីខ្លះ ទាំងការមានផ្ទៃពោះ និងការលេបថ្នាំគ្រាប់ពន្យារកំណើតសុទ្ធតែមានការប្រឈមនឹងគ្រោះថ្នាក់ខ្ពស់។ ស្ត្រីទាំងនេះគួរប្រើវិធីសាស្ត្រផ្សេងទៀតក្នុងការពន្យារកំណើត។

ស្ត្រីកម្រមានផ្ទៃពោះណាស់នៅពេលកំពុងប្រើថ្នាំពន្យារកំណើត។ ប៉ុន្តែ បើវាកើតឡើងមែន **ឈប់លេបថ្នាំភ្លាម**។ ព្រោះវាអាចប៉ះពាល់ដល់ទារកក្នុងផ្ទៃ។

ការស្លាប់ដែលទាក់ទងនឹងការលេបថ្នាំពន្យារកំណើត គឺជាការកម្រណាស់។ ជាមធ្យម ការមានផ្ទៃពោះ និងការសម្រាលកូន មានគ្រោះថ្នាក់៥០ដងច្រើនជាងការប្រើថ្នាំគ្រាប់ពន្យារកំណើត។

*ក្នុងចំណោមស្ត្រី១៥.០០០នាក់ដែលមានផ្ទៃពោះ ពួកគេទាំងអស់អាចស្លាប់ដោយសារបញ្ហាផ្សេងៗ នៅពេលមានផ្ទៃពោះ ឬពេលសម្រាលកូន។*



*ក្នុងចំណោមស្ត្រី១៥.០០០នាក់ ដែលប្រើថ្នាំគ្រាប់ពន្យារកំណើត មានតែម្នាក់ប៉ុណ្ណោះដែលអាចស្លាប់ដោយបញ្ហាដែលទាក់ទងនឹងការប្រើថ្នាំនេះ។*



*សន្និដ្ឋាន ៖ ការប្រើថ្នាំគ្រាប់ពន្យារកំណើតមានសុវត្ថិភាពជាងការមានផ្ទៃពោះ។*

## ថ្នាំគ្រាប់ពន្យារកំណើតបន្ទាន់

បើមានហេតុផលអ្វីមួយដែលធ្វើឲ្យអ្នកប្រើមធ្យោបាយពន្យារកំណើតរបស់អ្នកមិនបានត្រឹមត្រូវ មុនពេលរួមភេទ អ្នកនៅតែអាចជៀសវាងការមានផ្ទៃពោះបាន ដោយការលេបថ្នាំពន្យារកំណើតប្រភេទខ្លះ ក្នុងកម្រិតខ្ពស់ជាងធម្មតា ឬដោយប្រើថ្នាំគ្រាប់ពិសេសដែលត្រូវបានផលិតឡើងសម្រាប់គោលបំណងនេះ ភ្លាមៗបន្ទាប់ពីមានការរួមភេទ។ មើលទំ.៣៩៥។

# តើអ្នកណាខ្លះដែលមិនគួរលេបថ្នាំគ្រាប់ពន្យារកំណើត?

ស្ត្រីដែលមានរោគសញ្ញាណាមួយដូចខាងក្រោមនេះ មិនគួរលេប(ឬចាក់)ថ្នាំពន្យារកំណើតទេ ៖

- ស្ត្រីដែលរដូវមកយឺត ដែលគិតថាគាត់អាចមានផ្ទៃពោះ។



- **មានការឈឺចាប់យ៉ាងខ្លាំងនៅជើងម្ខាង។** នេះអាចបណ្តាលមកពីមានការរលាកសរសៃវ៉ែន (ការរលាកសរសៃវ៉ែន ឬមានដុំកំណកឈាម)។ កុំប្រើថ្នាំគ្រាប់ពន្យារកំណើត។ (ស្ត្រីដែលមានសរសៃវ៉ែនរីកប៉ោង ហើយគ្មានការរលាក ជាធម្មតាអាចប្រើថ្នាំគ្រាប់ពន្យារកំណើតបានដោយគ្មានបញ្ហា។ ប៉ុន្តែពួកគេគួរឈប់លេបវា បើសរសៃវ៉ែននោះក្លាយជាមានការរលាក)។





- **ជំងឺដាច់សរសៃឈាមខួរក្បាល។** ស្ត្រីដែលមានរោគសញ្ញាណាមួយនៃជំងឺដាច់សរសៃឈាមខួរក្បាល(ទំ.៣២៧) មិនគួរលេបថ្នាំគ្រាប់ពន្យារកំណើតទេ។

- **ជំងឺរលាកថ្លើម(ទំ.១៧២) ជំងឺថ្លើមក្រិន(ទំ.៣២៨) ឬជំងឺថ្លើមផ្សេងៗទៀត។** ស្ត្រីដែលមានបញ្ហាទាំងនេះ ឬដែលភ្នែករបស់គាត់មានពណ៌លឿងក្នុងអំឡុងពេលមានផ្ទៃពោះ មិនគួរប្រើថ្នាំគ្រាប់ពន្យារកំណើតទេ។ ជាការប្រសើរ មិនគួរលេបថ្នាំគ្រាប់ពន្យារកំណើតរយៈពេលមួយឆ្នាំ បន្ទាប់ពីមានជំងឺរលាកថ្លើម។

- **ជំងឺមហារីក។** បើអ្នកមានជំងឺនេះ ឬមានការសង្ស័យថាមានជំងឺមហារីកដោះឬស្បូន កុំប្រើថ្នាំគ្រាប់ពន្យារកំណើត។ មុននឹងចាប់ផ្តើមលេបថ្នាំគ្រាប់ពន្យារកំណើត ពិនិត្យមើលដោះរបស់អ្នកដោយហ្មត់ចត់(មើលទំ.២៧៩)។ នៅមណ្ឌលសុខភាពខ្លះ អ្នកអាចទទួលការពិនិត្យយ៉ាងសាមញ្ញម៉្យាង (Pap smear) ដើម្បីរកមើលជំងឺមហារីកមាត់ស្បូនបាន។ មិនទាន់មានការបញ្ជាក់ថាថ្នាំគ្រាប់ពន្យារកំណើតអាចបណ្តាលឲ្យកើតមហារីកដោះឬស្បូនទេ។ ប៉ុន្តែបើមានជំងឺមហារីករួចទៅហើយ នោះថ្នាំនេះអាចធ្វើឲ្យជំងឺមហារីកកាន់តែធ្ងន់ធ្ងរថែមទៀត។



បញ្ហាសុខភាពមួយចំនួនអាចមានសភាពកាន់តែធ្ងន់ធ្ងរថែមទៀត នៅពេលប្រើថ្នាំគ្រាប់ពន្យារកំណើត។ បើអ្នកមានបញ្ហាណាមួយដូចខាងក្រោមនេះ នោះការប្រសើរគួរត្រូវប្រើមធ្យោបាយផ្សេងវិញ បើអាច ៖

- **ជំងឺប្រកាំង**(ទំ.១៦២)។ ស្ត្រីដែលមានជំងឺប្រកាំង មិនគួរលេបថ្នាំគ្រាប់ពន្យារកំណើតទេ។ ប៉ុន្តែ ចំពោះការឈឺក្បាលធម្មតាដែលអាចបាត់ទៅវិញដោយការប្រើថ្នាំអាស្ពីរីន គឺអាចប្រើថ្នាំគ្រាប់ពន្យារកំណើតបាន។

- **ជំងឺបេះដូង**(ទំ.៣២៥)

- **ជំងឺលើសឈាម**(ទំ.១២៥)

បើអ្នកមានជំងឺរបេង ទឹកនោមផ្អែម បញ្ហាថង់ទឹកប្រមាត់ ជំងឺតម្រងនោម ឬជំងឺឆ្កួតជ្រូក ជាការប្រសើរបំផុត អ្នកគួរសួរដំបូន្មានពីគ្រូពេទ្យមុននឹងប្រើថ្នាំគ្រាប់ពន្យារកំណើត។ ទោះជាយ៉ាងនេះក៏ដោយ ស្ត្រីភាគច្រើនដែលមានជំងឺទាំងនេះ អាចប្រើថ្នាំគ្រាប់ពន្យារកំណើតដោយមិនមានបញ្ហាអ្វីឡើយ។

# ការប្រុងប្រយត្ន័សម្រាប់ស្ត្រីដែលប្រើថ្នាំគ្រាប់ពន្យារកំណើត

១. ហាមជក់បារី ជាពិសេសបើអ្នកមានអាយុលើសពី៣៥ឆ្នាំ។ វាអាចបណ្តាលឲ្យមានបញ្ហាបេះដូង។

២. ពិនិត្យដោះឲ្យបានហ្មត់ចត់ ជារៀងរាល់ខែ ដើម្បីរកមើលការមានដុំ ឬមានរោគសញ្ញាមហារីក (មើល ទំ.២៧៩)

៣. បើអាច វាស់សម្ពាធ ឈាមរបស់អ្នករៀងរាល់៦ខែម្តង។





៤. ប្រុងប្រយ័ត្នចំពោះរាល់បញ្ហាដែលបានរៀបរាប់នៅទំព័រ២៨៨ ជាពិសេស ៖

- ការឈឺក្បាលប្រកាំងយ៉ាងខ្លាំង និងជាញឹកញាប់(ទំ.១៦២)។
- ការវិលមុខ ឈឺក្បាល ឬការបាត់បង់ស្មារតី ដែលធ្វើឲ្យពិបាកមើល និយាយ ឬកំរើកផ្នែកណាមួយនៃមុខ ឬដងខ្លួន (មើល ជំងឺដាច់សរសៃឈាមខួរក្បាល ទំ.៣២៧)។
- ការឈឺចាប់ដោយមានការរលាកនៅជើង ឬត្រគាក (អាចមានដុំឈាមកក)។
- ការឈឺចាប់ក្នុងទ្រូងយ៉ាងខ្លាំង ឬឈឺជាប់ៗគ្នា (មើល បញ្ហាបេះដូង ទំ.៣២៥)។

បើមានបញ្ហាណាមួយខាងលើនេះកើតឡើង ត្រូវឈប់លេបថ្នាំ ហើយទៅពិគ្រោះយោបល់ជាមួយគ្រូពេទ្យ។ ពន្យារកំណើតដោយមធ្យោបាយដទៃទៀត ព្រោះថាបញ្ហាទាំងនេះក៏ធ្វើឲ្យការមានផ្ទៃពោះមានគ្រោះថ្នាក់ផងដែរ។

## សំនួរនិងចំលើយអំពីថ្នាំគ្រាប់ពន្យារកំណើត

| | | |
|---|---|---|
|  | អ្នកខ្លះអះអាងថាថ្នាំគ្រាប់ពន្យារកំណើតបណ្តាលឲ្យកើតជំងឺមហារីក។ តើនេះពិតឬទេ? | **ទេ! ប៉ុន្តែ បើមានជំងឺមហារីកដោះ ឬស្បូនរួចទៅហើយ នោះការលេបថ្នាំនេះអាចធ្វើឲ្យដុំមហារីក លូតលាស់កាន់តែឆាប់រហ័ស។** |
| ? | តើស្ត្រីអាចមានកូនវិញទេ បើគាត់ឈប់លេបថ្នាំនេះ? | **អាច! (ជួនកាលមានការពន្យារពេល១ឬ២ខែ មុនពេលដែលគាត់អាចមានផ្ទៃពោះ)។** |
|  | បើស្ត្រីបានប្រើថ្នាំគ្រាប់ពន្យារកំណើត តើឱកាសនៃការមានកូនភ្លោះ ឬមានកូនមិនគ្រប់លក្ខណៈ មានកាន់តែខ្ពស់មែនឬទេ? | **ទេ។ ស្ត្រីដែលបានប្រើថ្នាំគ្រាប់ពន្យារកំណើត មានឱកាសនៃការមាន បញ្ហានេះដូចគ្នានឹងស្ត្រីដែលមិនប្រើថ្នាំគ្រាប់ពន្យារកំណើតដែរ។** |
|  | តើនេះជាការពិតឬ ដែលថាទឹកដោះម្តាយនឹងស្ងួតបើគាត់ចាប់ផ្តើមលេបថ្នាំគ្រាប់ពន្យារកំណើត? | **ស្ត្រីមួយចំនួនមានការផលិតទឹកដោះតិចជាងមុន នៅពេលប្រើថ្នាំនេះ។ ដូច្នេះជាការប្រសើរបំផុត គួរតែប្រើមធ្យោបាយពន្យារកំណើតដទៃទៀត ពេលកំពុងបំបៅដោះកូន ហើយក្រោយមកចាំប្តូរមកប្រើថ្នាំគ្រាប់វិញ។ ឬគាត់អាចលេប "ថ្នាំគ្រាប់កម្រិតស្រាល" (ទំ.៣៩៥) ដែលមានជាតិអ័រម៉ូនតិចតួច ដែលជាធម្មតាវាមិនប៉ះពាល់ដល់ទឹកដោះម្តាយឡើយ។** |

សម្រាប់ព័ត៌មានអំពីការជ្រើសរើសថ្នាំគ្រាប់ពន្យារកំណើត មើលទំព័រ៣៩៤ និង៣៩៥។

# មធ្យោបាយផ្សេងទៀតនៃការពន្យារកំណើត



**ស្រោមអនាម័យ** គឺជាស្រោមកៅស៊ូស្តើងសម្រាប់ស្រោបប្រដាប់ភេទរបស់បុរស។ វាការពារទឹកកាមរបស់បុរសមិនឲ្យចូលទៅក្នុងទ្វារមាស និងស្បូនរបស់ស្ត្រី ក្នុងពេលរួមភេទ។ ស្រោមអនាម័យដែលផលិតពីកៅស៊ូ ក៏មាន**ប្រសិទ្ធិភាពបំផុតក្នុងការបង្ការជំងឺកាមរោគ និងមេរោគអេដស៍/ជំងឺអេដស៍ដែរ។** ស្រោមអនាម័យគួរត្រូវបានពាក់ទៅលើលិង្គរបស់បុរស នៅពេលវាឡើងរឹង ប៉ុន្តែត្រូវតែមុនពេលវាប៉ះពាល់ជាមួយប្រដាប់ភេទរបស់ស្ត្រី។ បន្ទាប់ពីចេញទឹកកាម បុរសត្រូវកាន់ទប់ស្រោមអនាម័យ រួចដកលិង្គចេញពីប្រដាប់ភេទរបស់ស្ត្រី នៅពេលដែលលិង្គនៅរឹងនៅឡើយ។ បន្ទាប់មកដោះស្រោមអនាម័យចេញ ដោយមិនឲ្យមានការកំពុបទឹកកាមចេញឡើយ។ ចងបិទមាត់វាឲ្យជិត ហើយបោះវាចោលទៅក្នុងធុងសំរាម។ គូស្វាមីភរិយាគប្បីប្រើស្រោមអនាម័យថ្មីៗគ្រប់ពេលរួមភេទ។ ទុកស្រោមអនាម័យនៅកន្លែងត្រជាក់ស្ងួត និងមិនត្រូវពន្លឺថ្ងៃ។ ស្រោមអនាម័យពីកញ្ចប់ចាស់ៗ ឬពីកញ្ចប់រហែក គឺប្រហែលជាងាយរហែក។



**ស្រោមអនាម័យសម្រាប់ស្ត្រី** គឺជាស្រោមប្លាស្ទិកស្តើង ដែលដាក់ចូលក្នុងទ្វារមាសរបស់ស្ត្រី។ កងយឺតនៅខាងចុងបិទជិតនៃស្រោមអនាម័យនេះ ធ្វើឲ្យវាអាចដាក់ជាប់នៅក្នុងទ្វារមាស។ កងមួយទៀតដែលបើកចំហនៅចុងម្ខាងទៀតនៃស្រោមអនាម័យនេះ នឹងស្ថិតនៅខាងក្រៅ ដោយគ្របពីលើបបូរទ្វារមាស។ ស្រោមអនាម័យនេះអាចដាក់ចូលក្នុងទ្វារមាសពេលណាក៏បាន មុនពេលរួមភេទ ហើយគួរយកចេញវិញភ្លាមបន្ទាប់ពីរួមភេទរួច។ ស្រោមមួយគួរប្រើវាតែម្តងប៉ុណ្ណោះ ពីព្រោះវាអាចរហែក បើគេលាងសម្អាតវាហើយប្រើប្រាស់ឡើងវិញ។ ប៉ុន្តែការប្រើប្រាស់ស្រោមអនាម័យស្ត្រីឡើងវិញ ក៏នៅតែប្រសើរជាងការមិនប្រើស្រោមអនាម័យដែរ។ ស្រោមអនាម័យស្ត្រីគឺជាមធ្យោបាយដ៏មានប្រសិទ្ធភាពបំផុតមួយ ដែលគ្រប់គ្រងដោយស្ត្រីដើម្បីបង្ការការមានផ្ទៃពោះ និងជំងឺកាមរោគ ដែលរួមទាំងមេរោគអេដស៍/ជំងឺអេដស៍ផងដែរ។



**សន្ទះដ្យ៉ាហ្វ្រាម** គឺជាពែងរាក់មួយ ធ្វើពីកៅស៊ូទន់ ដែលស្ត្រីពាក់វានៅក្នុងទ្វារមាសរបស់ពួកគេ។ ស្ត្រីអាចដាក់វាចូលពេលណាក៏បាន ហើយគួរតែទុកវាចោលក្នុងនោះយ៉ាងតិច៦ម៉ោង ក្រោយពេលរួមភេទរួច។ សន្ទះដ្យ៉ាហ្វ្រាមមានទំហំខុសៗគ្នា។ បុគ្គលិកសុខាភិបាលជំនាញអាចណែនាំទំហំណាមួយដែលត្រូវនឹងស្ត្រីម្នាក់ៗ។ ក្រោយពេលប្រើរួច ស្ត្រីគួរលាងសម្អាតសន្ទះដ្យ៉ាហ្វ្រាមនេះ ដោយប្រើសាប៊ូនិងទឹក ហើយហាលវាឲ្យស្ងួត។ ទុកវានៅកន្លែងស្អាតហើយស្ងួត។ ជាធម្មតាសន្ទះដ្យ៉ាហ្វ្រាមមួយប្រើបានប្រហែលរយៈពេល២ឆ្នាំ។ ពិនិត្យវាឲ្យបានទៀតទាត់ ដើម្បីរកមើលក្រែងមានប្រហោង ដោយបញ្ចាំងឆ្លុះវាជាមួយនឹងពន្លឺថ្ងៃ។ បើមានប្រហោងទោះបីជាតូចយ៉ាងណាក៏ដោយ ក៏ត្រូវប្រើសន្ទះដ្យ៉ាហ្វ្រាមថ្មីវិញ។




**ថ្នាំសម្លាប់មេជីវិតឈ្មោល** គឺជាថ្នាំពពុះៗ ថ្នាំគ្រាប់ ក្រែម ឬចាហួយ ដែលគេដាក់នៅក្នុងទ្វារមាសមុនពេលរួមភេទ។ ថ្នាំសម្លាប់មេជីវិតឈ្មោលនេះ សម្លាប់មេជីវិតរបស់បុរសមុនពេលវាអាចចូលទៅក្នុងស្បូន។ វាមិនអាចបង្ការជំងឺកាមរោគ ឬមេរោគអេដស៍/ជំងឺអេដស៍ទេ។ ថ្នាំគ្រាប់គួរដាក់ទៅក្នុងទ្វារមាសរយៈពេល១០ទៅ១៥នាទី មុនពេលរួមភេទ។ ថ្នាំពពុះ ចាហួយ ឬក្រែមនឹងមានប្រសិទ្ធិភាពបំផុត បើគេដាក់វាទៅក្នុងទ្វារមាសភ្លាមៗមុនពេលរួមភេទ។ បន្ថែមថ្នាំសម្លាប់មេជីវិតឈ្មោលរាល់ពេលដែលអ្នករួមភេទ។ បន្ទាប់ពីរួមភេទ មិនត្រូវលាងសម្អាតថ្នាំសម្លាប់មេជីវិតឈ្មោលចេញទេ ទុកវាឲ្យនៅក្នុងនោះរយៈពេលយ៉ាងតិច៦ម៉ោង។ ថ្នាំសម្លាប់មេជីវិតឈ្មោលខ្លះអាចបណ្តាលឲ្យមានការរមាស់ ឬក្រហាយនៅក្នុងទ្វារមាស។



**កងដាក់ក្នុងស្បូន** គឺជាវត្ថុតូចមួយដែលត្រូវបានដាក់បញ្ចូលទៅក្នុងស្បូនដោយបុគ្គលិកសុខាភិបាលឬឆ្មបដែលបានទទួលការបណ្តុះបណ្តាល។ កងដាក់ក្នុងស្បូនបង្ការមិនឲ្យទឹកកាមបុរសទៅបង្កកំណើតជាមួយពងញីរបស់ស្ត្រី។ កងដាក់ក្នុងស្បូនដែលគេប្រើញឹកញាប់បំផុត គឺកង Copper T380-A ដែលអាចដាក់នៅក្នុងស្បូនបានរហូតដល់១០ឆ្នាំ។ កងដាក់ក្នុងស្បូនប្រភេទផ្សេងៗទៀត អាចស្ថិតនៅក្នុងស្បូនបានរហូតដល់៥ឆ្នាំ។ កងដាក់ក្នុងស្បូនអាចត្រូវបានដាក់នៅពេលដែលស្ត្រីនិងបុគ្គលិកសុខាភិបាលរបស់គាត់ប្រាកដថាស្ត្រីនោះគ្មានផ្ទៃពោះ និងគ្មានរោគសញ្ញានៃការបង្ករោគក្នុងទ្វារមាស ឬជំងឺកាមរោគទេ។ ស្ត្រីអាចសុំឲ្យបុគ្គលិកសុខាភិបាលឬឆ្មបជំនាញ យកកងដាក់ក្នុងស្បូនចេញគ្រប់ពេលដែលគាត់ចង់ផ្លាស់ប្តូរមធ្យោបាយពន្យារកំណើត ឬគាត់ចង់មានផ្ទៃពោះវិញ។ កងដាក់ក្នុងស្បូនមិនបង្ការជំងឺកាមរោគទេ។

### វិធីសាស្ត្រវដ្តរដូវ

វិធីសាស្ត្រនេះមិនសូវប្រាកដក្នុងការបង្ការការមានផ្ទៃពោះទេ ប៉ុន្តែវាមានគុណសម្បត្តិត្រង់ថាវាមិនចំណាយប្រាក់កាស។ **វាទំនងជាមានប្រសិទ្ធភាពចំពោះស្ត្រីដែលមានរដូវទៀងទាត់ រៀងរាល់២៨ថ្ងៃម្តង។** ម្យ៉ាងទៀតប្តីប្រពន្ធត្រូវតែតាំងចិត្តមិនរួមភេទដោយគ្មានការការពារ រយៈពេលមួយអាទិត្យ ជារៀងរាល់ខែ។

ជាធម្មតាស្ត្រីម្នាក់ៗមានឱកាសមានផ្ទៃពោះតែក្នុងរយៈពេល៨ថ្ងៃប៉ុណ្ណោះ ក្នុងវដ្តរដូវប្រចាំខែរបស់គាត់ ដែលជា "ថ្ងៃបង្កកំណើត"។ ថ្ងៃទាំង៨នេះ គឺស្ថិតនៅពាក់កណ្តាលរដូវរបស់គាត់ គឺចាប់ផ្តើមនៅថ្ងៃទី១០ ដោយរាប់ពីថ្ងៃទីមួយនៃការធ្លាក់ឈាមរដូវ។ ដើម្បីជៀសវាងការមានផ្ទៃពោះ ស្ត្រីមិនគួររួមភេទជាមួយបុរសរបស់គាត់ក្នុងអំឡុងពេល៨ថ្ងៃនេះទេ។ ក្នុងអំឡុងពេលខុសពី៨ថ្ងៃនេះ គាត់មិនទំនងជាអាចមានផ្ទៃពោះទេ។

ដើម្បីជៀសវាងការច្រឡំ ស្ត្រីគួរគូសចំណាំនៅលើប្រតិទិនអំពីថ្ងៃទាំង៨ដែលគាត់មិនគួររួមភេទ។

ឧទាហរណ៍ ៖ ឧបមាថា រដូវរបស់អ្នកចាប់ផ្តើមនៅថ្ងៃទី៥ ខែឧសភា។ រាប់ថ្ងៃនោះ ជាថ្ងៃទី១។

គូសរបៀបនេះ

បន្ទាប់មក រាប់១០ថ្ងៃ។ ដោយចាប់ផ្តើមជាមួយថ្ងៃទី១០ គូសបន្ទាត់ពីក្រោម៨ថ្ងៃបន្ទាប់ ដូចនេះ




**ក្នុងរយៈពេល"ថ្ងៃបង្កកំណើត"ទាំង៨ថ្ងៃនេះ មិនត្រូវរួមភេទទេ។**

ឥឡូវនេះ ឧបមាថារដូវបន្ទាប់របស់អ្នក ចាប់ផ្តើមនៅថ្ងៃទី១ ខែមិថុនា។ គូសតាមរបៀបដដែល ដូចនេះ

ដូចលើកមុនដែរ រាប់១០ថ្ងៃ ហើយគូសបន្ទាត់ពីក្រោម៨ថ្ងៃបន្ទាប់ ដែលអ្នកនឹងមិនរួមភេទ។




បើប្តីប្រពន្ធ ជៀសវាងរួមភេទ ដោយប្រុងប្រយត្ន័ទាំងអស់គ្នា ក្នុងរយៈពេល៨ថ្ងៃនេះ ជារៀងរាល់ខែ នោះពួកគេនឹងអាចបង្ការការមានផ្ទៃពោះបានជាច្រើនឆ្នាំ។ ទោះជាយ៉ាងនេះក៏ដោយ មានតែប្តីប្រពន្ធតិចតួចប៉ុណ្ណោះដែលអាចប្រើវិធីសាស្ត្រនេះបានជោគជ័យយូរអង្វែង។ នេះមិនមែនជាវិធីសាស្ត្រដែលប្រាកដទាំងស្រុងនោះទេ លុះត្រាតែគេប្រើវារួមជាមួយ វិធីសាស្ត្រដទៃទៀត ដូចជាការប្រើសន្ទះដ្យ៉ាហ្វ្រាម ឬស្រោមអនាម័យ ជាពិសេសពីថ្ងៃចុងក្រោយនៃការមានឈាមរដូវរហូតដល់ផុតថ្ងៃបង្កកំណើត។

## វិធីសាស្ត្រពិនិត្យមើលទឹករំអិល

នេះជាវិធីសាស្ត្រដែលស្រដៀងនឹងវិធីសាស្ត្រវដ្តរដូវដែរ។ ស្ត្រីអាចធ្វើការកំណត់អំពីពេលដែលគាត់អាចមានផ្ទៃពោះ ដោយ ពិនិត្យមើលទឹករំអិលក្នុងទ្វារមាសរបស់គាត់ជារៀងរាល់ថ្ងៃ។ វិធីនេះមានប្រសិទ្ធភាពគួរសមសម្រាប់ ប្ដីប្រពន្ធខ្លះ ប៉ុន្តែក៏គ្មានប្រសិទ្ធភាពចំពោះប្ដីប្រពន្ធខ្លះទៀតដែរ។ ជាទូទៅ វិធីសាស្ត្រនេះមិនអាចចាត់ទុកថាជាវិធីសាស្ត្រដែលប្រាកដ ក្នុងការបង្ការការមានផ្ទៃពោះនោះទេ ប៉ុន្តែវាមិនចំណាយលុយកាក់ និងគ្មានការប្រឈមនឹងគ្រោះថ្នាក់ផ្សេងៗ ក្រៅពីការ មានផ្ទៃពោះប៉ុណ្ណោះទេ។ ប៉ុន្តែ វិធីសាស្ត្រនេះពិបាកអនុវត្តណាស់ បើស្ត្រីមានការបង្ករោគក្នុងទ្វារមាស ដោយមានការ ធ្លាក់សជាច្រើន ឬបើគាត់មានរដូវមិនទៀងទាត់ ឬបើគាត់ប្រើទឹកថ្នាំលាងសម្អាតទ្វារមាសជាញឹកញាប់។

ជារៀងរាល់ថ្ងៃ លើកលែងតែក្នុងអំឡុងពេលមានធ្លាក់ឈាមរដូវ ស្ត្រីគួរពិនិត្យមើលទឹករំអិលពីទ្វារមាសរបស់គាត់។ ចាប់យកទឹករំអិលបន្តិចពីទ្វារមាសរបស់អ្នក ដោយម្រាមដៃស្អាត ហើយសាកល្បងទាញសន្ទឹងវាចន្លោះមេដៃ និងចង្អុល ដៃរបស់អ្នក ដូចនេះ ៖

បើទឹករំអិលនោះស្អិតដូចជរ័ការ មិនរអិល ឬអន្លាយ នោះអ្នកប្រហែលជាមិនអាចមានផ្ទៃពោះទេ ហើយអាច បន្តការរួមភេទបាន។

នៅពេលទឹករំអិលចាប់ផ្តើមរអិល ឬអន្លាយ ដូចទឹក ស៊ុត ឬបើវាយឺតសន្ទឹងនៅចន្លោះម្រាមដៃរបស់អ្នក នោះ អ្នកអាចមានផ្ទៃពោះ បើអ្នករួមភេទ។ ដូច្នេះ **មិនត្រូវ រួមភេទទេ នៅពេលទឹករំអិលរបស់អ្នករអិល ឬអាចលាត សន្ទឹង ឬរហូតដល់៤ថ្ងៃបន្ទាប់ពីវាឈប់រអិល ឬឈប់ សន្ទឹង ហើយប្រែជាស្អិតវិញ។**





ជាធម្មតាទឹករំអិលនឹងក្លាយទៅជារអិលៗក្នុងរយៈពេលពីរបីថ្ងៃនៅចន្លោះថ្ងៃមករដូវរបស់អ្នក។ ថ្ងៃទាំងនេះគឺជាថ្ងៃ ដែលអ្នកមិនគួររួមភេទជាមួយបុរសរបស់អ្នក បើអ្នកប្រើវិធីសាស្ត្រវដ្តរដូវដូចរៀបរាប់ខាងលើនេះ។

ដើម្បីឲ្យកាន់តែប្រាកដ ប្រើវិធីសាស្ត្រពិនិត្យទឹករំអិល និងវិធីសាស្ត្រវដ្តរដូវជាមួយគ្នា។ ដើម្បីឲ្យកាន់តែប្រាកដ ថែមទៀត មើលខាងក្រោម។

## វិធីរួមបញ្ចូលគ្នា

បើអ្នកចង់ឲ្យកាន់តែប្រាកដថានឹងគ្មានផ្ទៃពោះនោះ ការប្រើវិធីសាស្ត្រពីរ ក្នុងពេលជំណាលគ្នា អាចជួយអ្នកបាន។ វិធីសាស្ត្រពិនិត្យទឹករំអិល ឬវិធីសាស្ត្រវដ្តរដូវ រួមជាមួយការប្រើស្រោមអនាម័យ សន្ទះដ្យ៉ាហ្វ្រាម ថ្នាំពពុះសម្លាប់មេជីវិត ឈ្មោល គឺមានភាពប្រាកដជាងការប្រើវិធីសាស្ត្រណាមួយតែមួយមុខ។ ដូចគ្នានេះដែរ បើបុរសប្រើស្រោមអនាម័យ ហើយស្ត្រីប្រើសន្ទះដ្យ៉ាហ្វ្រាម ឬថ្នាំពពុះសម្លាប់មេជីវិតឈ្មោលនោះ ឱកាសនៃការមានផ្ទៃពោះមានកម្រិតទាបបំផុត។

**ថ្នាំចាក់ពន្យារកំណើត។** ចពោះមធ្យោបាយពន្យារកំណើតមួយនេះ ស្ត្រីបានទទួលការចាក់ថ្នាំជាតិអ័រម៉ូន ជារៀងរាល់១ខែ ទៅ៣ខែ ជាធម្មតានៅតាមមណ្ឌលសុខភាព ឬនៅគ្លីនិកផែនការគ្រួសារ ដោយអ្នកម្នាក់ដែលចេះចាក់ថ្នាំនេះ។ ស្ត្រីអាចចាក់ថ្នាំលើកទីមួយនៅពេលណាក៏បាន ឲ្យតែស្ត្រីនោះនិងបុគ្គលិកសុខាភិបាលរបស់គាត់ ប្រាកដថាស្ត្រីនោះគ្មានផ្ទៃពោះ។ ការចាក់ថ្នាំនេះអាចបង្ការបានភ្លាមៗនូវការមានផ្ទៃពោះ បើចាក់ក្នុងរយៈពេល៥ថ្ងៃ បន្ទាប់ពីចាប់ផ្តើមមានឈាមរដូវ។ បើចាក់នៅថ្ងៃទី៦ ឬលើសពីនេះ បន្ទាប់ពីចាប់ផ្តើមមករដូវ នោះស្ត្រីនិងដៃគូគួរប្រើស្រោមអនាម័យ ឬមិនរួមភេទរយៈពេល២អាទិត្យបន្ទាប់។ សម្រាប់ព័ត៌មានបន្ថែម មើលទំព័រ៣៩៦។





**ការដាក់កងនៅដៃ** គឺជាបំពង់ទន់តូចៗ មួយ ពីរ ឬប្រាំមួយដើម ដែលត្រូវបានដាក់នៅខាងក្រោមស្បែកនៃដៃរបស់ស្ត្រី។ បំពង់ទាំងនេះមានជាតិអ័រម៉ូនប្រូហ្គេស្ទីន ហើយអាចបង្ការការមានផ្ទៃពោះ បានពី៦ខែ ទៅ៥ឆ្នាំ អាស្រ័យទៅតាមប្រភេទកង។ កងនេះត្រូវតែដាក់បញ្ចូលនិងយកចេញដោយបុគ្គលិកសុខាភិបាលដែលបានទទួលការបណ្តុះបណ្តាលត្រឹមត្រូវ ហើយជាធម្មតាត្រូវធ្វើនៅតាមគ្លីនិក ឬនៅមណ្ឌលផែនការគ្រួសារ។ គេអាចដាក់វានៅពេលណាក៏បាន ឲ្យតែស្ត្រីនោះនិងបុគ្គលិកសុខាភិបាលរបស់គាត់ ប្រាកដថាស្ត្រីនោះគ្មានផ្ទៃពោះ។ បើស្ត្រីកំពុងបំបៅដោះកូន កងនេះអាចត្រូវបានដាក់ក្នុងរយៈពេល៦អាទិត្យបន្ទាប់ពីការសម្រាលកូន។ សម្រាប់ព័ត៌មានបន្ថែម មើលទំព័រ៣៩៧។

## វិធីសាស្ត្រសម្រាប់អ្នកដែលមិនចង់មានកូនតទៅទៀត

**ការវះកាត់បញ្ឈប់កំណើតអចិន្ត្រៃយ៍។** បុរសនិងស្ត្រីដែលមិនចង់មានកូនតទៅទៀត អាចធ្វើការវះកាត់មួយ ដែលមានសុវត្ថិភាពនិងងាយស្រួល។ នៅប្រទេសជាច្រើន ការវះកាត់នេះត្រូវបានផ្តល់ជូនដោយគ្មានការបង់ថ្លៃ។ សូមសើបសួរនៅមណ្ឌលសុខភាព។

- **សម្រាប់បុរស** ការវះកាត់របៀបនេះត្រូវបានគេហៅថា ចងបំពង់មេជីវិតឈ្មោល។ វាអាចធ្វើបានដោយងាយនិងរហ័សនៅក្នុងបន្ទប់គ្រូពេទ្យ ឬនៅមណ្ឌលសុខភាព ដោយមិនបាច់ប្រើថ្នាំសន្លប់។ មានការវះតូចមួយនៅទីនេះ ដើម្បីអាចកាត់និងចងបំពង់មេជីវិតឈ្មោលដែលមកពីពងស្វាសរបស់បុរស។ ពងស្វាសមិនត្រូវបានកាត់យកចេញទេ។



ការវះកាត់នេះមិនប៉ះពាល់ដល់សមត្ថភាពផ្លូវភេទរបស់បុរសទេ។ ទឹកកាមរបស់គាត់ចេញមកដូចធម្មតា ប៉ុន្តែគ្មានមេជីវិតឈ្មោល។

- **សម្រាប់ស្ត្រី** ការវះកាត់នេះត្រូវបានគេហៅថាការចងដៃស្បូន។ មានវិធីម៉្យាង គឺត្រូវវះតូចមួយនៅពោះផ្នែកខាងក្រោម ដើម្បីអាចកាត់និងចងបំពង់ដែលចេញពីអូវ៉ែ ឬកន្លែងបង្កើតពងញី។ ជាធម្មតាគេអាចធ្វើការវះកាត់នេះនៅក្នុងបន្ទប់គ្រូពេទ្យ ឬនៅមណ្ឌលសុខភាព ដោយមិនបាច់ឲ្យស្ត្រីដេកលក់ទេ។ ទោះបីជាតាមធម្មតាវាមានជោគជ័យក៏ដោយ ក៏ការវះកាត់នេះមានការប្រឈមនឹងការបង្ករោគជាងជាងការវះកាត់លើបុរស។



ការវះកាត់នេះមិនប៉ះពាល់ដល់ការមករដូវ ឬសមត្ថភាពផ្លូវភេទរបស់ស្ត្រីទេ ហើយវាអាចធ្វើឲ្យការរួមភេទកាន់តែស្រួលថែមទៀត ព្រោះគាត់មិនចាំបាច់ព្រួយបារម្ភអំពីការមានផ្ទៃពោះទៀតទេ។

# វិធីសាស្ត្របុរាណក្នុងការបង្ការការមានផ្ទៃពោះ

សហគមន៍នីមួយៗមានវិធីសាស្ត្របុរាណរៀងខ្លួនក្នុងការបង្ការ ឬបញ្ឈប់ការមានផ្ទៃពោះ។ វិធីខ្លះនៃវិធីទាំងនេះអាចជួយកម្រិតចំនួនកូនដែលប្ដីប្រពន្ធមាន ប៉ុន្តែជាទូទៅវាមិនមានប្រសិទ្ធភាពដូចវិធីសាស្ត្រទំនើបទេ។ វិធីសាស្ត្របុរាណខ្លះអាចធ្វើឲ្យមានគ្រោះថ្នាក់ ហើយខ្លះទៀតគ្មានប្រសិទ្ធភាពសោះ។ ឧទាហរណ៍ ការលាងផ្នែកខាងក្នុងទ្វារមាស ឬការនោមបន្ទាប់ពីរួមភេទ មិនអាចបង្ការការមានផ្ទៃពោះបានទេ។

ការដកលឹង្គចេញ ។ បុរសដកលឹង្គរបស់គាត់ចេញពីទ្វារមាសរបស់ស្ត្រី មុនពេលចេញមេជីវិតឈ្មោល។ វិធីសាស្ត្រនេះប្រសើរជាងការមិនប្រើវិធីសាស្ត្រណាមួយសោះ ប៉ុន្តែវាមិនមែនតែងតែមានប្រសិទ្ធភាពនោះទេ។ ពេលខ្លះបុរសមិនអាចដកលឹង្គចេញមុនពេលគាត់ចេញទឹកកាមឡើយ។ បើទោះជាបុរសដកចេញក្រៅទាន់ពេលក៏ដោយ ក៏ទឹករំអិលដែលមានមេជីវិតឈ្មោល អាចជ្រាបចេញពីលឹង្គរបស់គាត់ មុនពេលចេញទឹកកាម និងអាចបណ្ដាលឲ្យមានផ្ទៃពោះបាន។

ការបំបៅដោះកូនក្នុងរយៈពេល៦ខែដំបូង។ ការបំបៅដោះកូនគឺជាវិធីសាស្ត្រ ដែលមានប្រសិទ្ធភាពក្នុងការពន្យារកំណើត តែនៅពេលដែលលក្ខខណ្ឌទាំងបីនេះជាការពិតប៉ុណ្ណោះ ៖



១. កូនរបស់ស្ត្រីមានអាយុតិចជាង៦ខែ។
២. ស្ត្រីមិនទាន់មានការធ្លាក់រដូវប្រចាំខែនៅឡើយ ចាប់តាំងពីការសម្រាលកូនមក។
៣. ស្ត្រីបំបៅដោះកូនដោយទឹកដោះម្ដាយតែមួយមុខប៉ុណ្ណោះ ហើយបំបៅទារកនៅពេលដែលវាឃ្លាន ទាំងពេលថ្ងៃនិងយប់ ដោយមានចន្លោះពេលបំបៅនីមួយៗមិនលើសពី៦ម៉ោង។ ទារកនឹងមិនដេកពេញមួយយប់ ដោយមិនបានបៅ។

វិធីសាស្ត្រប្រើស្នោរ។ នេះគឺជាវិធីសាស្ត្របុរាណមួយដែលគ្មានគ្រោះថ្នាក់ ហើយជួនកាលមានប្រសិទ្ធភាពដែរ។ អ្នកមិនអាចប្រាកដថាវានឹងអាចបង្ការការមានផ្ទៃពោះ ជារៀងរាល់ពេលនោះទេ ប៉ុន្តែវាអាចប្រើបាននៅពេលមិនអាចរកមធ្យោបាយផ្សេងៗទៀតបាន។

អ្នកត្រូវការស្នោរមួយដុំ និង**ទឹកខ្មេះ** ឬ**ទឹកក្រូចឆ្មា** ឬ**អំបិល**។

ស្នោរសមុទ្រ ឬស្នោរសិប្បនិមិត្ត ក៏អាចប្រើបានដូចគ្នា។ បើអ្នកគ្មានស្នោរទេ សាកល្បងប្រើដុំសំឡី គ ឬក្រណាត់ទន់ៗ ៖




- ការលាយ ៖

    ទឹកខ្មេះ២ស្លាបព្រាបាយ និងទឹកស្អាតមួយពែង

    **ឬ**

    ទឹកក្រូចឆ្មា១ស្លាបព្រាកាហ្វេ និងទឹកស្អាតមួយពែង

    **ឬ**

    អំបិល១ស្លាបព្រា និងទឹកស្អាត៤ស្លាបព្រា



- ជ្រលក់ស្នោរនេះដោយវត្ថុរាវទាំងនេះ
- ដាក់ស្នោរជ្រលក់នោះទៅក្នុងទ្វារមាសឲ្យជ្រៅ មុនពេលរួមភេទ។ អ្នកអាចដាក់វាចូលមុនរហូត១ម៉ោង។
- ទុកស្នោរនៅក្នុងនោះយ៉ាងតិច៦ម៉ោង ក្រោយពេលរួមភេទរួច។ បន្ទាប់មកយកវាចេញ។ បើអ្នកពិបាកយកចេញ លើកក្រោយគួរចងខ្សែអំបោះ ដែលអាចឲ្យអ្នកទាញវាចេញបាន។



គេអាចលាងសម្អាតស្នោរសម្រាប់ប្រើលើកក្រោយទៀត បានជាច្រើនដង។ ទុកវានៅកន្លែងស្អាត។ អ្នកអាចលាយទឹកទុកជាមុន ហើយទុកវានៅក្នុងដប។